# ខ្លឹមសារសង្ខេបប្រតិបត្តិ
# ស្តីពី
# សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០

ននននននន

## ១- ក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ចឆ្នាំ ២០២០

តាមការព្យាករណ៍ កំណើនសេដ្ឋកិច្ចកម្ពុជានឹងសម្រេចបានក្នុងអត្រា ៦,៥% ដែលកំណើននេះមានការថមថយ បើធៀបទៅនឹងកំណើនឆ្នាំ ២០១៩ ដែលត្រូវបានប៉ាន់ស្មានថាអាចសម្រេចបាន ៧,១% ដែលធ្វើឱ្យ ផសស ថ្លៃបច្ចុប្បន្នឆ្នាំ ២០២០ ស្ថិតនៅក្នុងរង្វង់ **១១៩ ០៣៤ ២២៩** លានរៀល សមមូលនឹងប្រមាណ **២៩ ៣៦២** លានដុល្លារអាមេរិក ហើយ ផសស សម្រាប់មនុស្សម្នាក់ត្រូវបានរំពឹងថានឹងកើនឡើងដល់ **១ ៨១៦** ដុល្លារអាមេរិក ធៀបនឹង **១ ៦៧៩** ដុល្លារ អាមេរិក ក្នុងឆ្នាំ ២០១៩។ កំណើននេះត្រូវបានទ្រទ្រង់ដោយៈ

**(ទី១)**-កំណើននៃវិស័យឧស្សាហកម្មត្រូវបានព្យាករថានឹងមានការថមថយមកក្នុងរង្វង់អត្រា ៨,៩% ក្នុងឆ្នាំ ២០២០ ធៀបនឹង ១០,៧% ក្នុងឆ្នាំ ២០១៩ ដោយសារការរំពឹងទុកនូវកំណើនយឺតនៃអនុវិស័យកាត់ដេរ និងកំណើនយឺតបន្តិចនៃអនុវិស័យសំណង់ ទោះបីជាអនុវិស័យឧស្សាហកម្មមិនមែនកាត់ដេរ ទាំងសម្រាប់បម្រើឱ្យការនាំចេញ និងទីផ្សារក្នុងស្រុកអាចសម្រេចបានកំណើនល្អប្រសើរជាងឆ្នាំ ២០១៩ បន្តិចក្តី។ អនុវិស័យកាត់ដេរត្រូវបានព្យាករថានឹងមានកំណើនទាប ដោយសារការថមថយកំណើននៃសេដ្ឋកិច្ចពិភពលោក និងការរំពឹងទុកនូវផលប៉ះពាល់ដែលអាចបណ្តាលមកពីភាពមិនច្បាស់លាស់នៃប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មជាមួយដៃគូមួយចំនួន។ ជាមួយគ្នានេះដែរ បើយោងតាមនិន្នាការក្នុងពេលថ្មីៗនេះ អនុវិស័យសំណង់អាចប្រឈមនឹងការកែតម្រូវផ្នែកទីផ្សារ ដែលនឹងអាចធ្វើឱ្យកំណើននៃវិស័យនេះមានការថមថយខ្លះ។ យ៉ាងណាមិញ អនុវិស័យឧស្សាហកម្មមិនមែនកាត់ដេរ ដូចជា ម្ហូបអាហារនិងភេសជ្ជៈ ឧស្សាហកម្មដំឡើងយានយន្ត គ្រឿងបង្គុំអេឡិកត្រូនិក គ្រឿងបន្លាស់ គ្រឿងសង្ហារិម និងស៊ីម៉ង់ត៍ជាដើម ទាំងសម្រាប់បម្រើឱ្យការនាំចេញ និងតម្រូវការទីផ្សារក្នុងស្រុក នឹងមានសន្ទុះកំណើនខ្ពស់ទាំងក្នុងទិដ្ឋភាពនៃការពង្រីកការវិនិយោគដែលមានស្រាប់ និងទាំងក្នុងទិដ្ឋភាពនៃការវិនិយោគថ្មី។

(**ទី២**)-វិស័យសេវាកម្មត្រូវបានព្យាករថានឹងមានកំណើនយឺតក្នុងរង្វង់៦,៤% ធៀបនឹង៦,៧% ក្នុងឆ្នាំ ២០១៩ ដោយសារការរំពឹងទុកនូវកំណើនយឺតនៃអនុវិស័យអចលនទ្រព្យ ខណៈអនុវិស័យលក់ដុំ-រាយ និង អនុវិស័យសណ្ឋាគារ និងភោជនីយដ្ឋាន នៅមានកំណើនល្អប្រសើរ។ អនុវិស័យសណ្ឋាគារ និងភោជនីយដ្ឋាន អាចសម្រេចបានកំណើនប្រហាក់ប្រហែលនឹងឆ្នាំ ២០១៩ ដែលឆ្លុះបញ្ចាំងតាមរយៈកំណើននៃចំនួនភ្ញៀវទេសចរ អន្តរជាតិ ពិសេសមកពីតំបន់អាស៊ី ដោយសារការលើកទឹកចិត្តឱ្យមានការបើកជើងហោះហើរត្រង់កាន់តែច្រើន និងការដាក់ចេញនូវគោលនយោបាយនានាក្នុងការទាក់ទាញភ្ញៀវទេសចរបន្ថែម។ អនុវិស័យលក់ដុំ-រាយនៅ រក្សាកំណើនល្អប្រសើរ ដែលគាំទ្រដោយកំណើននៃការប្រើប្រាស់ក្នុងស្រុក ដែលឆ្លុះបញ្ចាំងតាមរយៈការកើនឡើង នៃប្រាក់ចំណូលរបស់ប្រជាពលរដ្ឋ។ ដោយឡែក អនុវិស័យអចលនទ្រព្យត្រូវបានព្យាករថានឹងមានកំណើន យឺតដោយសារការរំពឹងទុកនៃការថមថយលើតម្រូវការសំណង់អគារដែលមានថ្លៃខ្ពស់ និង

(**ទី៣**)-វិស័យកសិកម្មអាចសម្រេចបានកំណើនប្រហាក់ប្រហែលទៅនឹងឆ្នាំ ២០១៩ ក្នុងរង្វង់១,៧%។ ប៉ុន្តែផ្អែកតាមការវិវត្តក្នុងរយៈពេលថ្មីៗកន្លងមកនេះ កំណើននេះអាចថមថយខ្លះ ដោយសារការបន្តកំណើនយឺត នៃអនុវិស័យដំណាំ បើទោះបីអនុវិស័យនេសាទ និងចិញ្ចឹមសត្វមានកំណើនខ្ពស់ជាងឆ្នាំមុនបន្តិចក្តី។ អនុវិស័យ ដំណាំត្រូវបានរំពឹងថានឹងអាចបន្តកំណើនទាបប្រហាក់ប្រហែលនឹងឆ្នាំមុន ដោយសារកំណើនផលិតភាពទាប ភាពមិនអំណោយផលនៃកត្តាអាកាសធាតុ និងភាពមានកម្រិតនៃការវិនិយោគលើវិស័យកែច្នៃកសិផល ថ្លៃដើម ផលិតកម្មខ្ពស់ធៀបនឹងប្រទេសជិតខាង ភាពទន់ខ្សោយនៃហេដ្ឋារចនាសម្ព័ន្ធគាំទ្រ និងសមត្ថភាពស្ថាប័ន។ ដោយឡែក អនុវិស័យនេសាទត្រូវបានរំពឹងថានឹងមានកំណើនលើសពីឆ្នាំ ២០១៩ បន្តិច ដែលត្រូវបានជំរុញ ដោយការបន្តកំណើននៃអនុវិស័យវារីវប្បកម្ម ស្របតាមនិន្នាការកើនឡើងនៃការវិនិយោគពីសំណាក់វិស័យ ឯកជន និងការចូលរួមពីដៃគូអភិវឌ្ឍន៍។ អនុវិស័យចិញ្ចឹមសត្វត្រូវបានព្យាករថានឹងមានកំណើនលើសពីឆ្នាំមុន បន្តិច ដោយសារតែការពង្រីកផលិតកម្មជ្រូក និងមាន់តាមបែបពាណិជ្ជកម្ម ក្នុងទម្រង់ជាកិច្ចសន្យា រវាងកសិករ ខ្នាតមធ្យម និងក្រុមហ៊ុនឯកជន។

**អត្រាអតិផរណាមធ្យមប្រចាំឆ្នាំ** ត្រូវបានប៉ាន់ស្មានថាស្ថិតក្នុងកម្រិតអាចគ្រប់គ្រងបាន ក្នុងអត្រា ២,៩% ក្នុងឆ្នាំ ២០២០ ស្របនឹងការរំពឹងទុកនៃការកើនឡើងខ្លះនូវថ្លៃម្ហូបអាហារ ជាពិសេសថ្លៃអង្ករ ខណៈដែលថ្លៃប្រេងលើទីផ្សារអន្តរជាតិត្រូវបានរំពឹងថានឹងបន្តធ្លាក់ចុះ ដែលអាចបណ្តាលមកពីឥទ្ធិពលនៃ សង្គ្រាមពាណិជ្ជកម្ម។ ចំណែកឯ **អត្រាប្តូរប្រាក់រៀល** គឺនៅតែបន្តស្ថិតនៅក្នុងរង្វង់ ៤ ០៥៤ រៀល ក្នុងមួយ ដុល្លារអាមេរិកក្នុងឆ្នាំ ២០២០ ដោយសារស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច, ជំនឿទុកចិត្តពីសំណាក់សាធារណជនលើ ការប្រើប្រាស់ប្រាក់រៀល តាមរយៈការអនុវត្តវិធានការលើកកម្ពស់ប្រាក់រៀលរបស់ធនាគារជាតិនៃកម្ពុជា និង ការបន្តពង្រឹងគោលនយោបាយគ្រប់គ្រងសាច់ប្រាក់ក្នុងវិស័យហិរញ្ញវត្ថុ។ **ឱនភាពគណនីចរន្ត (រួមបញ្ចូល បង្វែរ)** ត្រូវបានព្យាករថានឹងស្ថិតក្នុងអត្រា ៩,៣% នៃ ផសស ក្នុងឆ្នាំ ២០២០។ ភាពប្រសើរឡើងនៃគណនីចរន្ត នេះនឹងឆ្លុះបញ្ចាំងតាមរយៈការរំពឹងទុកអំពីកំណើននៃលំហូរប្រាក់បង្វែរឯកជនពីបរទេស និងភាពរួមតូចនៃ ឱនភាព សមតុល្យពាណិជ្ជកម្មដោយសារការថមថយនៃការនាំចូលវត្ថុធាតុដើមកាត់ដេរ ស្របទៅនឹងកំណើនទាបនៃ ការនាំចេញផលិតផលកាត់ដេរ។ **ទុនបម្រុងអន្តរជាតិសរុប** ត្រូវបានរំពឹងថានឹងបន្តកើនឡើងដល់ប្រមាណ **១៣ ០០៧** លានដុល្លារអាមេរិក ដែលធានាការនាំចូលបាន**៦,១** ខែ នៅឆ្នាំ ២០២០។

ជារួម ផ្អែកលើសូចនាករម៉ាក្រូសេដ្ឋកិច្ចដូចដែលបានកំណត់ខាងលើ យើងអាចនិយាយបានថា កម្ពុជានៅតែអាចបន្តសម្រេចបាននូវកំណើនសេដ្ឋកិច្ចកម្រិតខ្ពស់ ក្នុងរយៈពេលខ្លី និង មធ្យមខាងមុខ។ ទោះបីយ៉ាង-នេះក្តី, សេដ្ឋកិច្ចកម្ពុជាក៏នៅកំពុងតែប្រឈមនឹងហានិភ័យនិងបញ្ហាប្រឈមមួយចំនួន ទាំងទិដ្ឋភាពខាងក្នុងនិងខាងក្រៅ ដែលអាចនឹងធ្វើឱ្យប៉ះពាល់ដល់ចីរភាពនៃកំណើនសេដ្ឋកិច្ច និងបង្កភាពអាក់រអួលដល់កិច្ចអភិវឌ្ឍន៍របស់ខ្លួន។ ក្នុងន័យនេះ រាជរដ្ឋាភិបាលបានសម្រេចដាក់ចេញ និងបន្តរៀបចំដាក់ឱ្យអនុវត្តនូវវិធានការគោល-នយោបាយមុតស្រួចមួយចំនួនឱ្យបានទាន់ពេលវេលា ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពខ្ពស់ សំដៅជម្នះ និងដោះស្រាយចំពោះរាល់បញ្ហាប្រឈម និងហានិភ័យនានា ដើម្បីធានារក្សាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងសម្រេចបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ និងប្រកបដោយចីរភាព។

## ២-ក្របខណ្ឌគោលនយោបាយថវិកាឆ្នាំ ២០២០

ថវិកាឆ្នាំ ២០២០ ត្រូវបានរៀបចំដោយឈរលើមូលដ្ឋាននៃក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ដូចបានគូសបញ្ជាក់ខាងលើ តាមរយៈគោលនយោបាយវិត្តារកម្មថវិកា (Stimulus Budget) ដើម្បីគាំទ្រកំណើន និងបង្កើតការងារ ដែលមានគោលបំណងសំខាន់ៗ ដូចខាងក្រោម៖

- បន្តពង្រឹង**សន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ** និងសុវត្ថិភាពភូមិ-ឃុំ សម្រាប់ការរស់នៅដោយក្សេមក្សាន្តរបស់ប្រជាជន ព្រមទាំងការការពារឯករាជ្យ អធិបតេយ្យ និងបូរណភាពទឹកដីមិនឱ្យកម្លាំងណាមករំលោភបំពាន និងបំផ្លាញបានឡើយ
- បន្តធានាអនុវត្តគោលនយោបាយ ដើម្បីជំរុញ**កំណើន ការងារ សមធម៌ និងប្រសិទ្ធភាព** ក្នុងគោលដៅបែងចែកផ្លែផ្កាកំណើនប្រកបដោយសមធម៌ដល់គ្រប់ស្រទាប់វណ្ណៈនៃប្រជាជន
- បន្តធានានូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងសារពើពន្ធ ដើម្បីសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ចរឹងមាំប្រកបដោយបរិយាប័ន្ន និងចីរភាព ក្នុងបរិការណ៍នៃភាពមិនច្បាស់លាស់ និងលទ្ធភាពនៃការកើតមានហានិភ័យជាយថាហេតុ ព្រមទាំងបន្តធានាបាននូវអត្រាអតិផរណាដែលអាចគ្រប់គ្រងបាន និងស្ថិរភាពអត្រាប្តូរប្រាក់
- បន្តគាំទ្រការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ, ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ និងការកែទម្រង់វិស័យកងកម្លាំងប្រដាប់អាវុធ ព្រមទាំងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ
- ជំរុញការអនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥ ដែលរួមមាន ការដាក់ឱ្យអនុវត្តន៍សាកល្បងនូវក្របខណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមឆ្នាំ ២០២០-២០២២ និងក្របខណ្ឌថវិការយៈពេលមធ្យមឆ្នាំ ២០២០-២០២២ និងយុទ្ធសាស្ត្រពាក់ព័ន្ធផ្សេងទៀត ជាអាទិ៍៖ យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ ២០១៩-២០២៥, យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ ២០១៩-២០២៥ និង យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈឆ្នាំ ២០១៩-២០២៥
- ជំរុញការអនុវត្តន៍យុទ្ធសាស្ត្រគៀរគរចំណូលឆ្នាំ២០១៩-២០២៣

- ដាក់ឱ្យអនុវត្តន៍ក្របខណ្ឌចំណាយអន្តរាគមន៍ ប្រកបដោយប្រសិទ្ធភាព ទាំងក្នុងកម្រិតវិភាជ និងប្រតិបត្តិការ ក្នុងបរិការណ៍នៃការកើនឡើងនូវភាពមិនច្បាស់លាស់ និង លទ្ធភាពនៃការអាចកើតមានហានិភ័យមកលើសេដ្ឋកិច្ចកម្ពុជា
- បន្តគិតគូរលើការដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការស៊ីវិលក្នុងកម្រិតសមស្រប ដោយផ្អែកទៅលើសមិទ្ធកម្ម ឬគុណាធិបតេយ្យ ដើម្បីបន្តពង្រឹងសមត្ថភាពស្ថាប័ន និងអភិបាលកិច្ច ក្នុងគោលដៅធានាប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, គណនេយ្យភាព និងតម្លាភាពនៃការផ្តល់សេវាសាធារណៈ
- បន្តអនុវត្តន៍ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គមឆ្នាំ២០១៦-២០២៥ មានជាអាទិ៍ ការថែទាំសុខភាពមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន របបថែទាំសុខភាពសម្រាប់កម្មករ និងរបបឧបត្ថម្ភមាតុភាពសម្រាប់កម្មការិនី ព្រមទាំងរបបសន្តិសុខសង្គមផ្អែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈជាដើម។ល។
- បន្តអនុវត្តន៍យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈឆ្នាំ ២០១៩-២០២៣
- បន្តគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០១៦-២០២០ និងយុទ្ធសាស្ត្រជាតិស្តីពីបរិយាប័ន្នហិរញ្ញវត្ថុឆ្នាំ២០១៩-២០២៥
- ពន្លឿនការអនុវត្តឱ្យបានខ្លាំងក្លានូវវិធានការនៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ ២០១៥-២០២៥ តាមរយៈការគាំទ្រការអភិវឌ្ឍវិស័យឯកជន និងការកែលម្អថែមទៀតនូវភាពប្រកួតប្រជែងរបស់កម្ពុជា ពិសេស ការបង្កើនវិនិយោគសាធារណៈលើការអភិវឌ្ឍហេដ្ឋារចនា-សម្ព័ន្ធរូបវន្ត ដោយផ្តោតលើការតភ្ជាប់ក្នុងវិស័យដឹកជញ្ជូននិងវិស័យថាមពល ក៏ដូចជាការតភ្ជាប់វិស័យឌីជីថលក្នុងបរិបទនៃបដិវត្តន៍ឧស្សាហកម្មទី៤ ការបន្តកាត់បន្ថយថ្លៃអគ្គិសនីការលើកកម្ពស់កិច្ចសម្រួលពាណិជ្ជកម្ម និងការកាត់បន្ថយថ្លៃដើមផ្សេងៗក្នុងការធ្វើធុរកិច្ច
- បន្តជំរុញការអភិវឌ្ឍធនធានមនុស្ស តាមរយៈការបន្តលើកកម្ពស់គុណភាពអប់រំ និងការបណ្តុះ-បណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសទាំងកម្រិតទាប មធ្យម និងខ្ពស់ ដើម្បីផ្គត់ផ្គង់ពលករជំនាញប្រកបដោយផលិតភាពខ្ពស់ ឱ្យបានសមស្របទៅតាមតម្រូវការទីផ្សារ
- បន្តលើកកម្ពស់សេវាសុខាភិបាល តាមរយៈការបង្កើនការវិនិយោគបន្ថែម ទាំងលើអគារមន្ទីរពេទ្យសម្ភារបរិក្ខារ និងសមត្ថភាពមន្ត្រីសុខាភិបាល
- បន្តជំរុញការអភិវឌ្ឍវិស័យកសិកម្ម ដោយផ្តោតលើការបង្កើនផលិតភាព, ពិពិធកម្ម, ការកែច្នៃកសិផល និងពាណិជ្ជូបនីយកម្ម និង
- ការគាំទ្រដល់ការរៀបចំកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុបឱ្យទទួលបានជោគជ័យតាមការគ្រោងទុក។

ដើម្បីសម្រេចបាននូវគោលបំណងសំខាន់ៗខាងលើ ថវិកាឆ្នាំ ២០២០ ត្រូវបានរៀបចំឡើងដោយឈរលើ**អភិក្រម** និង**គោលការណ៍សំខាន់ៗ**ចំនួន ៩ ដូចខាងក្រោម៖

- គោរពឱ្យបាននូវក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច
- ធានាចីរភាព និងសមិទ្ធកម្មនៃចំណូល

- ការផ្សារភ្ជាប់ការប្រមូលចំណូល ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងលទ្ធផលការងារ ជាមួយនឹងការវិភាជថវិកា
- ការកំណត់លំដាប់អាទិភាព សំដៅលើកកម្ពស់ប្រសិទ្ធភាពនៃការវិភាជថវិកា
- ការយកចិត្តទុកដាក់លើមនុស្ស
- ការកំណត់តម្លៃដាក់ស្តែងនៃកម្មវិធី/សកម្មភាព
- ការផ្ទេរថវិកាឱ្យដល់អង្គភាពអនុវត្ត
- ការរក្សាតុល្យភាព និងចីរភាពថវិកា
- ការបន្តពង្រឹងភាពប្រុងប្រយ័ត្នខ្ពស់ក្នុងការគ្រប់គ្រងបំណុលសាធារណៈ។

## ៣-ក្របខណ្ឌថវិកាឆ្នាំ ២០២០

ឈរលើគោលការណ៍ខាងលើ ក៏ដូចជាក្នុងក្របខណ្ឌនៃកំណើនសេដ្ឋកិច្ចដែលត្រូវបានគ្រោងក្នុងរង្វង់ ៦,៥% ព្រមជាមួយនឹងសេណារីយ៉ូចំណូលដែលមានលក្ខណៈសុទិដ្ឋិនិយម និងដោយឈរលើមូលដ្ឋាននៃលទ្ធផលល្អប្រសើរនៃការអនុវត្តចំណូល ជាពិសេស ចំណូលគយ និងចំណូលពន្ធដារឆ្នាំ ២០១៨ និងឆ្នាំ ២០១៩ នេះ, ក្របខណ្ឌថវិកាឆ្នាំ ២០២០ ត្រូវបានរៀបចំឡើង ក្រោមការកំណត់ដូចតទៅ៖

| សូចនាករថវិកា | ២០១៨ | | ២០១៩ | ២០២០ |
|---|---|---|---|---|
| | ច្បាប់ | អនុវត្ត | ច្បាប់ | គ្រោង |
| **ចំណូលក្នុងប្រទេសថវិការដ្ឋ ឬ ថវិកាជាតិ (% ផសស)** | **18.82** | **22.28** | **19.51** | **22.13** |
| - ចំណូលចរន្ត (% ផសស) | 18.63 | 22.08 | 19.33 | 21.96 |
| **ចំណាយសរុបថវិការដ្ឋ ឬ ថវិកាជាតិ (% ផសស)** | **24.67** | **24.58** | **25.02** | **28.01** |
| - ចំណាយចរន្ត (% ផសស) | 16.14 | 16.48 | 16.49 | 16.65 |
| **អតិរេកចរន្ត (% ផសស)** | **2.49** | **5.61** | **2.84** | **5.31** |
| **ឱនភាពសរុប (% ផសស)** | **-5.86** | **-2.30** | **-5.51** | **-5.88** |

**<u>ចំណូលក្នុងប្រទេសថវិការដ្ឋ ឬ ថវិកាជាតិ</u>** ត្រូវបានគ្រោងចំនួន ២៦ ៣៣៦ ៤៤៣ លានរៀល ស្មើនឹង ២២,១៣% នៃ ផសស និងមានកំណើន ២៤,៣% ធៀបនឹងច្បាប់ឆ្នាំ ២០១៩ ចំណែកឯ **<u>ចំណាយសរុបថវិការដ្ឋ ឬ ថវិកាជាតិ</u>** ត្រូវបានគ្រោងចំនួន ៣៣ ៣៣៩ ៦៣៣ លានរៀល ស្មើនឹង ២៨,០១% នៃ ផសស និងមានកំណើន ២២,៧% ធៀបនឹងច្បាប់ឆ្នាំ ២០១៩។ ជាលទ្ធផល **<u>អតិរេកថវិកាចរន្ត</u>** អាចរក្សាបានក្នុងកម្រិតប្រមាណ **៥,៣១%** នៃ ផសស នៅឆ្នាំ ២០២០ និងមាន **<u>ឱនភាពថវិកាសរុប</u>** ស្មើនឹង **-៥,៨៨%** នៃ ផសស ស្របតាម **គោលនយោបាយវិត្ថារកម្មថវិកា** (Stimulus Budget)។ ឱនភាពនេះ ត្រូវបានបំពេញបន្ថែមដោយហិរញ្ញប្បទានក្រៅប្រទេសក្នុងទំហំ **៥,០៩%** នៃ ផសស, មូលនិធិទ្រទ្រង់ថវិកាប្រមាណ **០,២១%** នៃ ផសស និងប្រាក់បញ្ញើរាជរដ្ឋាភិបាលក្នុងទំហំ **០,៥៩%** នៃ ផសស ស្មើនឹង **៧០០ ០០០ លានរៀល ឬ សមមូលនឹង ១៧៣ លានដុល្លារអាមេរិក** ដែលត្រូវបានគ្រោងយកមកប្រើប្រាស់ដើម្បីត្រៀមលក្ខណៈអនុវត្តវិធានការឆ្លើយតបនឹងផលប៉ះពាល់នៃភាពមិនច្បាស់លាស់ពាក់ព័ន្ធនឹងប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មជាមួយដៃគូមួយចំនួន។

## ៤-គម្រោងចំណូល-ចំណាយថវិការដ្ឋ
## ៤.១-គម្រោងចំណូលថវិការដ្ឋ

| ចំណូលថវិកា (ឯកតាលានរៀល) | ២០១៩ | | ២០២០ | | % កំណើន |
|---|---|---|---|---|---|
| | ច្បាប់ | % ផសស | គ្រោង | % ផសស | |
| **សរុបចំណូលថវិការដ្ឋ ឬ ថវិកាជាតិ** | **26,759,996** | **24.64%** | **32,639,633** | **27.42%** | **22.0%** |
| *• ថ្នាក់ជាតិ* | 25,360,028 | 23.35% | 30,395,855 | 25.54% | 19.9% |
| *• ថ្នាក់ក្រោមជាតិ* | 1,399,968 | 1.29% | 2,243,778 | 1.88% | 60.3% |
| **១. ចំណូលចរន្តថវិការដ្ឋ** | **20,993,079** | **19.33%** | **26,143,102** | **21.96%** | **24.5%** |
| *ក. ចំណូលសារពើពន្ធថវិការដ្ឋ* | 18,230,617 | 16.79% | 23,177,453 | 19.47% | 27.1% |
| *- ថ្នាក់ជាតិ* | 16,879,000 | 15.54% | 21,091,145 | 17.72% | 25.0% |
| *- ថ្នាក់ក្រោមជាតិ* | 1,351,617 | 1.24% | 2,086,308 | 1.75% | 54.4% |
| *ខ. ចំណូលមិនមែនសារពើពន្ធថវិការដ្ឋ* | 2,762,462 | 2.54% | 2,965,649 | 2.49% | 7.4% |
| *- ថ្នាក់ជាតិ* | 2,714,111 | 2.50% | 2,808,179 | 2.36% | 3.5% |
| *- ថ្នាក់ក្រោមជាតិ* | 48,351 | 0.04% | 157,470 | 0.13% | 225.7% |
| **២. ចំណូលមូលធនថវិការដ្ឋ** | **5,766,917** | **5.31%** | **6,496,531** | **5.46%** | **12.7%** |
| *• ក្នុងប្រទេស* | 193,149 | 0.18% | 193,341 | 0.16% | 0.1% |
| *• ក្រៅប្រទេស* | 5,573,768 | 5.13% | 6,303,190 | 5.30% | 13.1% |

ក្នុងក្របខណ្ឌនៃគោលដៅខាងលើ រាជរដ្ឋាភិបាលត្រូវ**បង្កើនចំណូលសរុបថវិការដ្ឋ ឬ ចំណូលសរុបថវិកាជាតិ** ឱ្យស្មើនឹង ៣២ ៦៣៩ ៦៣៣ លានរៀល ក្នុងនោះ ចំណូលចរន្តថ្នាក់ជាតិឱ្យស្មើនឹង ២៣ ៨៩៩ ៣២៤ លានរៀល (ដែលរួមមាន ចំណូលសារពើពន្ធ ២១ ០៩១ ១៤៥ លានរៀល និង ចំណូលមិនមែនសារពើពន្ធ ២ ៨០៨ ១៧៩ លានរៀល)។ ដោយឡែក សម្រាប់ចំណូលមូលធនថវិការដ្ឋ ត្រូវបានគ្រោងចំនួន ៦ ៤៩៦ ៥៣១ លានរៀល, ត្រូវជា ៥,៤៦% នៃ ផសស គឺមានកំណើន ១២,៧% ធៀបនឹងច្បាប់ឆ្នាំ ២០១៩ ក្នុងនោះចំណូលមូលធនដោយហិរញ្ញប្បទានពីក្រៅប្រទេសស្មើនឹងប្រមាណជិត ១៩% នៃចំណាយថវិការដ្ឋសរុបឆ្នាំ ២០២០ ប៉ុណ្ណោះ។

## ៤.២-គម្រោងចំណាយថវិការដ្ឋ

សម្រាប់ឆ្នាំ ២០២០ **ចំណាយសរុបថវិការដ្ឋ** **ឬ** **ចំណាយសរុបថវិកាជាតិ** ត្រូវបានគ្រោងចំនួន **៣៣ ៣៣៩ ៦៣៣ លានរៀល** ត្រូវជា ២៨,០១% នៃ ផសស គឺមានកំណើន ២២,៧% ធៀបនឹងច្បាប់ឆ្នាំ ២០១៩ ដែលក្នុងនោះ (១)-**ចំណាយចរន្តថវិការដ្ឋមានចំនួន ១៩ ៨១៨ ៣០៦ លានរៀល** ត្រូវជា ១៦,៦៥% នៃ ផសស គឺមានកំណើន ១០,៧% ធៀបនឹងច្បាប់ឆ្នាំ ២០១៩ និង (២)-**ចំណាយមូលធនថវិការដ្ឋមានចំនួន ១៣ ៥២១ ៣២៧ លានរៀល** ត្រូវជា ១១,៣៦% នៃ ផសស គឺមានកំណើន ៤៦,១% ធៀបនឹងច្បាប់ឆ្នាំ ២០១៩។

| ចំណាយថវិកា (ឯកតាលានរៀល) | ២០១៩ | | ២០២០ | | % កំណើន |
|---|---|---|---|---|---|
| | ច្បាប់ | % ផសស | គ្រោង | % ផសស | |
| **សរុបចំណាយថវិការដ្ឋ ឬ ថវិកាជាតិ** | **27,164,996** | **25.02%** | **33,339,633** | **28.01%** | **22.7%** |
| *• ថ្នាក់ជាតិ* | 25,765,028 | 23.73% | 31,095,855 | 26.12% | 20.7% |
| *• ថ្នាក់ក្រោមជាតិ* | 2,199,636 | 2.03% | 3,329,236 | 2.80% | 51.4% |
| **១. ចំណាយចរន្តថវិការដ្ឋ** | **17,907,549** | **16.49%** | **19,818,306** | **16.65%** | **10.7%** |
| ***១.១. ថ្នាក់ជាតិ*** | 16,827,280 | 15.50% | 18,036,884 | 15.15% | 7.2% |
| *•បន្ទុកបុគ្គលិក* | 7,862,537 | 7.24% | 8,539,752 | 7.17% | 8.6% |
| *•ក្រៅបន្ទុកបុគ្គលិក* | 8,964,743 | 8.26% | 9,497,132 | 7.98% | 5.9% |
| ***១.២. ថ្នាក់ក្រោមជាតិ*** | **1,879,937** | **1.73%** | **2,866,880** | **2.41%** | **52.5%** |
| *•បន្ទុកបុគ្គលិក* | 472,565 | 0.44% | 599,128 | 0.50% | 26.8% |
| *•ក្រៅបន្ទុកបុគ្គលិក* | 1,407,372 | 1.30% | 2,267,752 | 1.91% | 61.1% |
| **២. ចំណាយមូលធនថវិការដ្ឋ** | **9,257,447** | **8.53%** | **13,521,327** | **11.36%** | **46.1%** |
| *- វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស* | 3,027,731 | 2.79% | 6,362,215 | 5.34% | 110.1% |
| *+ ក្នុងនោះចំណាយមូលធនថ្នាក់ក្រោមជាតិ* | 319,699 | 0.29% | 462,356 | 0.39% | 44.6% |
| *- ការទូទាត់ប្រាក់ខ្ចី* | 905,948 | 0.83% | 1,105,922 | 0.93% | 22.1% |
| *- វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស* | 5,323,768 | 4.90% | 6,053,190 | 5.09% | 13.7% |

### ៤.២.១-ថវិកាថ្នាក់ជាតិ

ថវិកាឆ្នាំ ២០២០ មានទិសដៅជាយុទ្ធសាស្ត្រកំណត់**ចំណាយថវិកាថ្នាក់ជាតិ**ឱ្យស្ថិតក្នុងកម្រិតចំនួន ៣១ ០៩៥ ៨៥៥ លានរៀល ត្រូវជា ២៦,១២% នៃ ផសស គឺមានកំណើន ២០,៧% ធៀបនឹងច្បាប់ឆ្នាំ ២០១៩ ដែលក្នុងនោះ **ចំណាយចរន្តថ្នាក់ជាតិ** មានចំនួន ១៨ ០៣៦ ៨៨៤ លានរៀល និង **ចំណាយមូលធនថ្នាក់ជាតិ**មានចំនួន ១៣ ០៥៨ ៩៧១ លានរៀល។

**ក. ចំណាយលើបន្ទុកបុគ្គលិក** ត្រូវបានគ្រោងចំនួន ៨ ៥៣៩ ៧៥២ លានរៀល សម្រាប់(១)-ការដំឡើង**បៀវត្សមូលដ្ឋាន**ក្នុងអត្រា **៧,០%** តាមតម្លៃឯកតាសន្ទស្សន៍ ២ ៥០០ រៀល ដោយអនុវត្តន៍ចាប់ពីខែមករា ឆ្នាំ ២០២០, (២)-ការដំឡើង**ប្រាក់បំណាច់មុខងារ**នឹងត្រូវអនុវត្តចាប់ពីខែមេសា ឆ្នាំ ២០២០ ដោយផ្តល់បន្ថែម **៣០ ០០០ រៀល** ជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ដែលមានប្រាក់បំណាច់មុខងារក្នុងកម្រិតក្រោម ៩៦០ ០០០ រៀល និង ចាប់ពីកម្រិត ៩៦០ ១០០ រៀល ដល់ ១ ១១០ ០០០ រៀល នឹងផ្តល់បន្ថែមចំនួន **២០ ០០០ រៀល**, (៣)-ការដំឡើងប្រាក់ឧបត្ថម្ភប្រចាំខែសម្រាប់**មន្ត្រីជាប់កិច្ចសន្យា** ពី ៦៥០ ០០០ រៀល ទៅដល់ **៦៧០ ០០០ រៀល** ដោយអនុវត្តន៍ចាប់ពីខែមករា ដល់ខែធ្នូ ឆ្នាំ ២០២០។

ជារួម នៅឆ្នាំ ២០២០ បៀវត្សអប្បបរមារបស់មន្ត្រីរាជការស៊ីវិល និង កងកម្លាំងប្រដាប់អាវុធ នឹងមានស្ថានភាពផ្លាស់ប្តូរដូចខាងក្រោម៖

- **បៀវត្សមន្ត្រីរាជការស៊ីវិល** នឹងត្រូវបានដំឡើងពីចំនួន ១ ១០០ ១០០ រៀល នៅឆ្នាំ ២០១៩ ដល់ប្រមាណ ១ ១៤២ ៥០០ រៀល នៅខែមករា ឆ្នាំ ២០២០, ហើយនឹងត្រូវបានដំឡើងដល់ប្រមាណ **១ ១៧២ ៥០០** រៀល ចាប់ពីខែមេសា ឆ្នាំ ២០២០;

- **ប្រាក់បៀវត្សគ្រូបង្រៀន និង គ្រូពេទ្យ** នឹងត្រូវបានដំឡើងពីចំនួន ១ ២០០ ១០០ រៀល នៅឆ្នាំ ២០១៩ ដល់ប្រមាណ ១ ២៤២ ៥០០ រៀល នៅខែមករា ឆ្នាំ ២០២០ ហើយនឹងត្រូវបានដំឡើងដល់ប្រមាណ **១ ២៧២ ៥០០** រៀល ចាប់ពីខែមេសា ឆ្នាំ ២០២០;
- **ប្រាក់បៀវត្សនគរបាល (ពលបាលត្រី)** នឹងត្រូវបានដំឡើងពីចំនួន ១ ១៨៤ ៥៧៧ រៀល (គិតបញ្ចូលទាំងរបបអង្គរ) នៅឆ្នាំ ២០១៩ ដល់ប្រមាណ ១ ២២៦ ៩៧៧ រៀល (គិតបញ្ចូលទាំងរបបអង្គរ) នៅខែមករា ឆ្នាំ ២០២០ ហើយនឹងត្រូវបានដំឡើងដល់ប្រមាណ **១ ២៥៦ ៩៧៧** រៀល (គិតបញ្ចូលទាំងរបបអង្គរ) ចាប់ពីខែមេសា ឆ្នាំ ២០២០;
- **ប្រាក់បៀវត្សយោធិន (ពលទោ)** នឹងត្រូវបានដំឡើងពីចំនួន ១ ០៥៥ ៩០០ រៀល (មិនគិតបញ្ចូលរបបអង្គរ) នៅឆ្នាំ ២០១៩ ដល់ប្រមាណ ១ ០៩៣ ៥០០ រៀល (មិនគិតបញ្ចូលរបបអង្គរ) នៅខែមករា ឆ្នាំ ២០២០ ហើយនឹងត្រូវបានដំឡើងដល់ ១ ១២៣ ៥០០ រៀល ចាប់ពីខែមេសា ឆ្នាំ ២០២០ បើគិតបញ្ចូលរបបអង្គរ ត្រូវជាប្រមាណ **១ ១៨១ ៩៧៧** រៀល។

ទន្ទឹមនេះ សម្រាប់ឆ្នាំ ២០២០ រាជរដ្ឋាភិបាលនឹងធ្វើការកែសម្រួលនូវកម្រិតអប្បបរមានៃប្រាក់បៀវត្សត្រូវជាប់ពន្ធ ក្នុងគោលបំណងផ្ដល់ការលើកទឹកចិត្ត និងលើកកម្ពស់កម្រិតជីវភាពរបស់មន្ត្រីរាជការស៊ីវិល គ្រូបង្រៀន គ្រូពេទ្យ នគរបាលជាតិ យោធិន ក៏ដូចជា កម្មករ និយោជិត ដែលទទួលបានប្រាក់បៀវត្សចាប់ពី ១ ៣០០ ០០០ រៀល ចុះ ឱ្យរួចផុតពីកាតព្វកិច្ចបង់ពន្ធលើប្រាក់បៀវត្ស។

ក្រៅពីបានដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ រាជរដ្ឋាភិបាលក៏បានគ្រោងថវិកាចំនួន**៤០ ប៊ីលានរៀល** ដោយឡែកផ្សេងទៀត សម្រាប់ផ្ដល់លទ្ធភាពដល់ក្រសួង-ស្ថាប័នអាចជ្រើសរើសមន្ត្រីមានសមត្ថភាព និងជំនាញខ្ពស់ចូលបម្រើការងាររដ្ឋ ដែលក្របខណ្ឌ និងគោលការណ៍នឹងត្រូវបានរៀបចំដាក់ឱ្យអនុវត្តន៍នៅក្នុងឆ្នាំ២០២០។ លើសពីនេះ ថវិកាចំនួន**៥០ប៊ីលានរៀល** ត្រូវបានគ្រោងសម្រាប់មូលនិធិថែទាំសុខភាពជូនមន្ត្រីរាជការស៊ីវិល កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ និងនិវត្តជន និងបានបន្តគ្រោងថវិកាចំនួន**៦ ប៊ីលានរៀល**ដើម្បីទ្រទ្រង់របបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ នៅក្នុងកញ្ចប់ថវិការបស់ក្រសួងសុខាភិបាល។ ចំពោះ**ប្រាក់សោធននិវត្តន៍** ក៏ត្រូវបានគ្រោងថវិកា**ចំនួន៦០ប៊ីលានរៀល** សម្រាប់ការដំឡើងរបបសោធនប្រចាំខែទាបបំផុតជូនដល់និវត្តជនដែលជាអតីតមន្ត្រីរាជការស៊ីវិល និងកង-កម្លាំងប្រដាប់អាវុធផងដែរ ក្នុងគោលដៅជួយគាំទ្រដល់ជីវភាពរបស់ពួកគាត់ ក៏ដូចជាការកាត់បន្ថយគម្លាតរបបសោធនរបស់និវត្តជន រវាងអ្នកទទួលបានសោធនទាប និងអ្នកទទួលបានសោធនខ្ពស់ និងរវាងនិវត្តជនថ្មី និងនិវត្តជនចាស់។

**ខ. <u>ចំណាយមិនមែនបន្ទុកបុគ្គលិក</u>** ត្រូវបានគ្រោងចំនួន ៩ ៤៩៧ ១៣២ លានរៀល, មានសមាមាត្រស្មើនឹង ៥២,៦៥% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ ត្រូវជា ៧,៩៨% នៃ ផសស គឺមានកំណើន ៥,៩% ធៀបនឹងច្បាប់ឆ្នាំ ២០១៩, ហើយត្រូវបានវិភាជដោយផ្អែកលើតម្រូវការ និងអាទិភាពចាំបាច់តាមវិស័យនីមួយៗ ដូចខាងក្រោម៖

## វិស័យរដ្ឋបាលទូទៅ

- លើកកម្ពស់ប្រសិទ្ធភាពការងារគ្រប់គ្រងចំណូល និងប្រមូលចំណូលសារពើពន្ធ
- គាំទ្រការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ
- គាំទ្រកំណែទម្រង់វិស័យដីធ្លី
- គាំទ្រ និងពង្រឹងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មឆ្នាំ ២០១៥-២០២៥
- គាំទ្រដល់ការប្រយុទ្ធប្រឆាំងអំពើពុករលួយ
- បង្កើនប្រសិទ្ធភាពនៃកិច្ចការទូត តាមរយៈបង្កើនការគាំទ្រផ្នែកហិរញ្ញវត្ថុដល់មន្ត្រីការទូត
- គាំទ្រដល់ការរៀបចំធ្វើជាម្ចាស់ផ្ទះនៃកិច្ចការប្រជុំកំពូល អាស៊ី-អឺរ៉ុប ឆ្នាំ ២០២០។

## វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ

- គាំទ្រដល់ការពង្រឹងសមត្ថភាពរបស់នគរបាល និងកងកម្លាំងប្រដាប់អាវុធ
- បន្តផ្តោតការយកចិត្តទុកដាក់លើជីវភាព និងសុខុមាលភាពកងកម្លាំងប្រដាប់អាវុធ
- បង្កើនការគាំទ្រដល់កិច្ចដំណើរការរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សាលាជម្រះក្តីគ្រប់-ជាន់ថ្នាក់ និងរដ្ឋបាលតុលាការ
- គាំទ្រកិច្ចដំណើរការរដ្ឋបាល និងអន្តរាគមន៍ផ្សេងៗ
- គាំទ្រដល់ដំណើរការនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- គាំទ្រការអនុវត្តគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព
- គាំទ្រដល់ការរៀបចំប្រព័ន្ធត្រួតពិនិត្យសន្តិសុខតាមច្រកព្រំដែន និងការផលិតលិខិតឆ្លងដែន
- បន្តគាំទ្រដល់ការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ស្ត្រី និងកុមារ
- បន្តគាំទ្រដល់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បន្តគាំទ្រសេវាឥតគិតថ្លៃរបស់គណៈមេធាវីកម្ពុជា។

## វិស័យសង្គមកិច្ច

- ពង្រឹងគុណភាព និងគាំទ្រសេវាអប់រំ
- លើកកម្ពស់វិស័យកីឡាជាតិ
- អភិវឌ្ឍន៍ជំនាញ និងវិស័យការងារ
- លើកកម្ពស់គុណភាព និងការទទួលបានសេវាសុខាភិបាល
- ទប់ស្កាត់អំពើហឹង្សាលើស្ត្រី និងកុមារ
- ឧបត្ថម្ភគាំទ្រដល់សមាគមអតីតយុទ្ធជន
- បង្កើនការឧបត្ថម្ភដល់មជ្ឈមណ្ឌលស្តារនីតិសម្បទាតាមបណ្តារាជធានី-ខេត្ត និងការឧបត្ថម្ភគាំទ្រមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្ម កាយសម្បទា ដើម្បីផ្តល់សេវាជូនជនពិការ
- ផ្តល់ថវិកាគាំទ្រដល់ការដោះស្រាយជីវភាពចំពោះជនក្រីក្រ និងចាស់ជរានៅតាមសហគមន៍
- ការពារ និងអភិរក្សធនធានធម្មជាតិ
- អភិរក្ស និងអភិវឌ្ឍន៍វប្បធម៌ជាតិ
- សុខដុមនីយកម្មសាសនា។

**វិស័យសេដ្ឋកិច្ច**

- បន្តការលើកកម្ពស់បច្ចេកទេសកសិកម្ម
- ជំរុញផលិតកម្មស្បៀង ពិសេសការចិញ្ចឹមសត្វ និងមច្ឆវប្បកម្ម
- ពង្រឹងការគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ច និងការបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើ និងជលផល
- បង្កើនការគាំទ្រដល់ការពង្រឹងប្រសិទ្ធភាពក្នុងការគ្រប់គ្រងធនធានរ៉ែគ្រប់ប្រភេទ
- ជំរុញការអភិវឌ្ឍទឹកស្អាត និងអនាម័យជនបទ
- ជួសជុល និងថែទាំប្រព័ន្ធធារាសាស្ត្រ
- ជំរុញការអភិវឌ្ឍផលិតផល និងការពង្រឹងគុណភាពសេវាទេសចរណ៍
- បន្តបើកទីផ្សារសម្រាប់ការនាំចេញរបស់កម្ពុជា
- បន្តជួសជុល ថែទាំផ្លូវ ស្ពាន និងផ្លូវលំជនបទ ព្រមទាំងការស្តារស្រះ ជីកស្រះ និងអណ្តូងទឹក ដើម្បីទប់ទល់នឹងគ្រោះរាំងស្ងួត
- ត្រួតពិនិត្យសុវត្ថិភាពចំណីអាហារ
- អភិវឌ្ឍន៍ប្រព័ន្ធរដ្ឋបាលអេឡិកត្រូនិក
- ពង្រឹងនូវក្របខណ្ឌ និងយន្តការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម
- អភិវឌ្ឍន៍ប្រព័ន្ធស្តង់ដា និងមាត្រាសាស្ត្រ។

លើសពីនេះ សម្រាប់ឆ្នាំ ២០២០ រាជរដ្ឋាភិបាលក៏បានគ្រោងថវិកា ឆ្លើយតបនឹងសកម្មភាពគាំពារសង្គម ដែលរួមមានជាអាទិ៍ដូចជា៖

- **បន្តគាំទ្រការថែទាំសុខភាពសម្រាប់កម្មករ៖** បានត្រៀមថវិកាក្នុងកញ្ចប់ថវិការបស់ក្រសួងសុខាភិបាល សម្រាប់ពង្រីកវិសាលភាពមូលនិធិសមធម៌ ដើម្បីផ្តល់លទ្ធភាពឱ្យកម្មករ ( ទាំងក្នុងប្រព័ន្ធ និង ក្រៅប្រព័ន្ធ ) ដែលមិនទាន់ជាសមាជិកបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស.) ទទួលបានរបបថែទាំសុខភាពដូចប្រជាជនដែលមានប័ណ្ណក្រីក្រដែរ;
- **បន្តការឧបត្ថម្ភមាតុភាពសម្រាប់កម្មករនិយោជិត៖** បានគ្រោងនៅក្នុងកញ្ចប់ថវិការបស់ក្រសួងសុខាភិបាលសម្រាប់បន្តបើកផ្តល់ប្រាក់ឧបត្ថម្ភជូនកម្មការិនី នៅក្រោយពេលសម្រាលកូន និងសម្រាកលំហែមាតុភាព;
- **ការបន្តនិរន្តរភាពមន្ទីរពេទ្យគន្ធបុប្ផា៖** បន្តផ្តល់ថវិកាសម្រាប់បង្កើន "**មូលនិធិគន្ធបុប្ផាកម្ពុជា**" បន្ថែមលើថវិកាដែលត្រូវផ្តល់ផ្ទាល់ទៅមន្ទីរពេទ្យគន្ធបុប្ផាសម្រាប់ចំណាយប្រតិបត្តិការឆ្នាំ ២០២០, ដើម្បីធានានិរន្តភាព គុណភាព និងប្រសិទ្ធភាព របស់មន្ទីរពេទ្យផង និងធានាការផ្តល់សេវាដោយមិនយកថ្លៃជូនដល់កុមារនៃគ្រួសារក្រីក្រផង;
- **ការបន្តសកម្មភាពរបស់រាជរដ្ឋាភិបាលក្នុងការចុះសួរសុខទុក្ខកម្មករ-កម្មការិនី** តាមបណ្តារោងចក្រសហគ្រាស ដើម្បីស្វែងយល់និងរកដំណោះស្រាយសមស្របជូនកម្មករ-កម្មការិនី ក៏ដូចជាជំរុញគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម;

- **កម្មវិធីផ្ទេរសាច់ប្រាក់សម្រាប់ស្ត្រីក្រីក្រមានផ្ទៃពោះ និងកុមារតូចៈ** បានគ្រោងថវិកាសម្រាប់ឧបត្ថម្ភ ពេលពិនិត្យផ្ទៃពោះ ចំនួន ៤ លើក, ១ លើក ៤ ម៉ឺនរៀល, ពេលសម្រាលកូននៅមណ្ឌលសុខភាព ឬពេទ្យរដ្ឋ ជូន ២០ម៉ឺនរៀល, ឧបត្ថម្ភ ១០ លើកទៀត ១លើក ៤ ម៉ឺនរៀល ពេលទៅទទួលថ្នាំបង្ការ រហូតដល់កុមារអាយុ ២ ឆ្នាំ។

**គ. <u>ចំណាយមូលធនថ្នាក់ជាតិ</u>** ត្រូវបានគ្រោងចំនួន ១៣ ០៥៨ ៩៧១ លានរៀល មានសមាមាត្រស្មើនឹង ៤២,០% នៃចំណាយថវិកាថ្នាក់ជាតិសរុប ត្រូវជា ១០,៩៧% នៃ ផសស គឺមានកំណើន ៤៦,១% ធៀបនឹងច្បាប់ឆ្នាំ ២០១៩។ គម្រោងវិនិយោគផ្ទាល់ដោយហិរញ្ញប្បទានក្នុងប្រទេសនៅថ្នាក់ជាតិមានកំណើន ១៧០,២% ធៀបនឹងច្បាប់ឆ្នាំ ២០១៩, ហើយត្រូវជា ៤,២២% នៃ ផសស គឺដោយសារការគ្រោងប្រើប្រាស់ក្នុងបរិបទនៃភាពមិនច្បាស់លាស់ពាក់ព័ន្ធនឹងប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មជាមួយដៃគូមួយចំនួន ដើម្បីជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ និងបង្កើតការងារជូនប្រជាពលរដ្ឋបន្ថែម ដោយដាក់ចេញនូវវិធានការអន្តរាគមន៍ដើម្បីស្រូបយកការប៉ះទង្គិចរយៈពេលខ្លី, ដោះស្រាយបញ្ហាជារចនាសម្ព័ន្ធ, ពង្រឹងភាពធន់នឹងវិបត្តិលើផ្នែកម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងបង្កើនប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃស្ថាប័នសាធារណៈ។ លើសពីនេះ ចំណាយលើហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តដែលគាំទ្រដល់កំណើនសេដ្ឋកិច្ច និងភាពប្រកួតប្រជែងកម្ពុជា ដែលមានគោលដៅផ្តល់ហិរញ្ញប្បទានដល់គម្រោង/កម្មវិធី ក្នុងវិស័យអាទិភាពដោយផ្តោតទៅលើៈ

- ការកសាង និងជួសជុលហេដ្ឋារចនាសម្ព័ន្ធ ផ្លូវថ្នល់ ស្ពាន លូ ព្រមទាំងការជួសជុលឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធដែលរងផលប៉ះពាល់ពីជំនន់ទឹកភ្លៀង រួមទាំងការកសាងហេដ្ឋារចនាសម្ព័ន្ធ ដូចជា ប្រព័ន្ធចម្រោះទឹកកខ្វក់ ប្រព័ន្ធលូ អូរ ប្រឡាយរំដោះទឹកភ្លៀង និងប្រព័ន្ធបង្ហូរទឹកកខ្វក់ ក្នុងខេត្តព្រះសីហនុ;
- ការបន្តស្តារ និងកសាងប្រព័ន្ធធារាសាស្ត្រ និងលើកកម្ពស់ប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រងធារាសាស្ត្រ ពិសេសលើកកម្ពស់ការគ្រប់គ្រង និងទប់ទល់នឹងទឹកជំនន់;
- ការបន្តកសាងហេដ្ឋារចនាសម្ព័ន្ធវិស័យអប់រំ និងបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ និងការ-សាងសង់ហេដ្ឋារចនាសម្ព័ន្ធចាំបាច់មួយចំនួនផ្សេងទៀត ពិសេសការសាងសង់អគារបន្ថែមនៅក្នុងមន្ទីរពេទ្យមួយចំនួន ដែលកំពុងមានការខ្វះខាត;
- ការបន្តអនុវត្តន៍សាកល្បងនូវកម្មវិធីសាច់ប្រាក់ពលកម្ម ( Cash For Work ) ដែលជាអន្តរាគមន៍ដោយត្រង់របស់រាជរដ្ឋាភិបាលក្នុងការបង្កើតការងារនៅទីជនបទ;
- ការបន្តវិនិយោគលើវិស័យអគ្គិសនី ដើម្បីបន្តពង្រីកវិសាលភាពនៃការផ្គត់ផ្គង់អគ្គិសនី និងបញ្ចុះថ្លៃអគ្គិសនីនៅជនបទ;
- ការបន្តផ្តល់ថវិកាគម្រោងវិនិយោគផ្ទាល់ក្នុងខេត្តត្បូងឃ្មុំ
- ការបន្តវិនិយោគលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធវិស័យកសិកម្ម និងការវិនិយោគលើការជំរុញផលិតកម្មស្បៀង ជាពិសេសការផលិតស្រូវ និងបន្លែ។

## ជាលទ្ធផលរួម ថវិកាថ្នាក់ជាតិត្រូវបានបែងចែកទៅតាមវិស័យទាំង ៤ ដូចខាងក្រោម៖

| ចំណាយថវិកាតាមវិស័យ (ឯកតាលានរៀល) | ២០១៩ | | ២០២០ | | % កំណើន |
|---|---|---|---|---|---|
| | ច្បាប់ | % ផសស | គ្រោង | % ផសស | |
| ១. វិស័យរដ្ឋបាលទូទៅ | 2,463,542 | 2.27% | 2,511,827 | 2.11% | 2.0% |
| ក. ចំណាយចរន្ត | 2,245,785 | 2.07% | 2,350,730 | 1.97% | 4.7% |
| -បន្ទុកបុគ្គលិក | 692,538 | 0.64% | 726,764 | 0.61% | 4.9% |
| -ក្រៅបន្ទុកបុគ្គលិក | 1,553,247 | 1.43% | 1,623,966 | 1.36% | 4.6% |
| ខ. ចំណាយមូលធន | 217,757 | 0.20% | 161,097 | 0.14% | -26.0% |
| -វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | 16,500 | 0.02% | 16,500 | 0.01% | 0.0% |
| -វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 201,257 | 0.19% | 144,597 | 0.12% | -28.2% |
| ២. វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ | 4,425,150 | 4.08% | 4,791,817 | 4.03% | 8.3% |
| ក. ចំណាយចរន្ត | 4,263,557 | 3.93% | 4,660,378 | 3.92% | 9.3% |
| -បន្ទុកបុគ្គលិក | 3,387,865 | 3.12% | 3,704,598 | 3.11% | 9.3% |
| -ក្រៅបន្ទុកបុគ្គលិក | 875,692 | 0.81% | 955,780 | 0.80% | 9.1% |
| ខ. ចំណាយមូលធន | 161,593 | 0.15% | 131,439 | 0.11% | -18.7% |
| -វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | 79,417 | 0.07% | 86,004 | 0.07% | 8.3% |
| -វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 82,176 | 0.08% | 45,435 | 0.04% | -44.7% |
| ៣. វិស័យសង្គមកិច្ច | 7,249,418 | 6.68% | 7,870,325 | 6.61% | 8.6% |
| ក. ចំណាយចរន្ត | 6,196,796 | 5.71% | 6,747,860 | 5.67% | 8.9% |
| -បន្ទុកបុគ្គលិក | 3,263,876 | 3.01% | 3,581,479 | 3.01% | 9.7% |
| -ក្រៅបន្ទុកបុគ្គលិក | 2,932,920 | 2.70% | 3,166,382 | 2.66% | 8.0% |
| ខ. ចំណាយមូលធន | 1,052,622 | 0.97% | 1,122,465 | 0.94% | 6.6% |
| -វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | 280,000 | 0.26% | 185,000 | 0.16% | -33.9% |
| -វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 772,622 | 0.71% | 937,465 | 0.79% | 21.3% |
| ៤. វិស័យសេដ្ឋកិច្ច | 6,620,459 | 6.10% | 7,329,311 | 6.16% | 10.7% |
| ក. ចំណាយចរន្ត | 1,506,888 | 1.39% | 1,556,835 | 1.31% | 3.3% |
| -បន្ទុកបុគ្គលិក | 518,258 | 0.48% | 526,912 | 0.44% | 1.7% |
| -ក្រៅបន្ទុកបុគ្គលិក | 988,630 | 0.91% | 1,029,923 | 0.87% | 4.2% |
| ខ. ចំណាយមូលធន | 5,113,572 | 4.71% | 5,772,476 | 4.85% | 12.9% |
| -វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | 845,858 | 0.78% | 846,783 | 0.71% | 0.1% |
| -វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 4,267,714 | 3.93% | 4,925,693 | 4.14% | 15.4% |

## ទំហំចំណាយថវិកាសរុបរបស់ក្រសួង-ស្ថាប័ន
## សម្រាប់ឆ្នាំ ២០២០ ធៀបនឹងឆ្នាំ ២០១៣




## ចំណាយថវិកាសរុបរបស់ក្រសួង-ស្ថាប័ន
## សម្រាប់ឆ្នាំ ២០១៣-២០២០
## (ចំណាយចរន្ត និង ចំណាយមូលធន)



## ៤.២.២-ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

| ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ (ឯកតាលានរៀល) | ២០១៩ | | ២០២០ | | % កំណើន |
|---|---|---|---|---|---|
| | ច្បាប់ | % ផសស | គ្រោង | % ផសស | |
| ចំណូលចរន្តថវិកាថ្នាក់ក្រោមជាតិ | 1,399,968 | 1.29% | 2,243,778 | 1.88% | 60.3% |
| • *ចំណូលសារពើពន្ធ* | 1,351,617 | 1.24% | 2,086,308 | 1.75% | 54.4% |
| • *ចំណូលមិនមែនសារពើពន្ធ* | 48,351 | 0.04% | 157,470 | 0.13% | 225.7% |
| សរុបចំណាយថវិកាថ្នាក់ក្រោមជាតិ | 2,199,636 | 2.03% | 3,329,236 | 2.80% | 51.4% |
| • *ចំណាយចរន្ត* | 1,879,937 | 1.73% | 2,866,880 | 2.41% | 52.5% |
| • *ចំណាយមូលធន* | 319,699 | 0.29% | 462,356 | 0.39% | 44.6% |
| ឱនភាពថវិកា | -799,668 | -0.74% | -1,085,458 | -0.91% | 35.7% |
| ឧបត្ថម្ភដល់ថ្នាក់ក្រោមជាតិ | 799,668 | 0.74% | 1,085,458 | 0.91% | 35.7% |
| • *រាជធានី-ខេត្ត* | 83,808 | 0.08% | 47,024 | 0.04% | -43.9% |
| • *មូលនិធិក្រុង-ស្រុក* | 192,060 | 0.18% | 235,117 | 0.20% | 22.4% |
| • *មូលនិធិឃុំ-សង្កាត់* | 523,800 | 0.48% | 607,386 | 0.51% | 16.0% |
| • *មូលនិធិអភិវឌ្ឍន៍ឃុំ-សង្កាត់* | 0 | 0.00% | 195,931 | 0.16% | 100.00% |

គម្រោងចំណូល-ចំណាយរបស់រដ្ឋបាលរាជធានី-ខេត្ត ក្រុង-ស្រុក និងឃុំ-សង្កាត់ខាងលើ បានធ្វើឱ្យមានឱនភាពថវិកាចំនួន ១ ០៨៥ ៤៥៨ លានរៀល ត្រូវជា ០,៩១% នៃ ផសស ដែលត្រូវបានគ្រោងឧបត្ថម្ភដោយថវិកាថ្នាក់ជាតិ ដែលការឧបត្ថម្ភនេះមានកំណើន ៣៥,៧% ធៀបនឹងច្បាប់ឆ្នាំ ២០១៩ ក្នុងនោះ: (១)-**ឧបត្ថម្ភរាជធានី-ខេត្ត** ចំនួន ៤៧ ០២៤ លានរៀល, (២)-**ឧបត្ថម្ភមូលនិធិក្រុង-ស្រុក** ចំនួន ២៣៥ ១១៧ លានរៀល មានកំណើន ២២,៤% ធៀបនឹងច្បាប់ឆ្នាំ ២០១៩ និង (៣)-**ឧបត្ថម្ភមូលនិធិឃុំ-សង្កាត់** ចំនួន ៦០៧ ៣៨៦ លានរៀល មានកំណើន ១៦,០% ធៀបនឹងច្បាប់ឆ្នាំ ២០១៩ និង**មូលនិធិអភិវឌ្ឍន៍ឃុំ-សង្កាត់** ចំនួន១៩៥ ៩៣១ លានរៀល ដែលជាការផ្ទេរធនធានបន្ថែមពីថវិការដ្ឋចំនួន ១% ក្នុង១ឆ្នាំ នៃចំណូលចរន្តថ្នាក់ជាតិជូនរដ្ឋបាលឃុំ-សង្កាត់ សម្រាប់ចំណាយអភិវឌ្ឍមូលដ្ឋានចាប់ពីឆ្នាំ ២០២០ ដល់ឆ្នាំ ២០២៣។ ការឧបត្ថម្ភធនបន្ថែមនេះនឹងធ្វើឱ្យទំហំមូលនិធិអភិវឌ្ឍឃុំ-សង្កាត់ នឹងកើនឡើងទ្វេដងនៅឆ្នាំ ២០២០ ពីប្រមាណ **៣៥ ០០០ ដុល្លារអាមេរិក** ជាមធ្យមក្នុង១ ឆ្នាំ ទៅប្រមាណជាង **៧០ ០០០ ដុល្លារអាមេរិក**ជាមធ្យមក្នុង១ ឆ្នាំ។

ជារួម គួរកត់សម្គាល់ថា ចំណាយថវិកាថ្នាក់ក្រោមជាតិ (ថវិការដ្ឋបាលរាជធានី-ខេត្ត រដ្ឋបាលក្រុង-ស្រុក និងរដ្ឋបាលឃុំ-សង្កាត់) ត្រូវបានបង្កើន**ជាង៤ដង** គឺពីប្រមាណតែចំនួន **៧៦៦ ប៊ីលានរៀល** នៅឆ្នាំ២០១៣ ឬសមមូលស្មើនឹង ១៩០ លានដុល្លារអាមេរិក ដែលមានសមាមាត្រស្មើនឹង៦,១%នៃចំណាយថវិការដ្ឋសរុប ហើយត្រូវជា១,២៥%នៃ ផសស ទៅដល់ប្រមាណចំនួន **៣ ៣២៩ ប៊ីលានរៀល** នៅឆ្នាំ២០២០ ឬសមមូលស្មើនឹង ៨២១ លានដុល្លារអាមេរិក ដែលមានសមាមាត្រស្មើនឹង១០,០%នៃចំណាយថវិការដ្ឋសរុប ហើយត្រូវជា ២,៨០% នៃ ផសស ក្នុងនោះ៖ (១).ថវិការដ្ឋបាលរាជធានី-ខេត្ត ត្រូវបានបង្កើនពីប្រមាណតែចំនួន **៥០២ ប៊ីលានរៀល** ឬសមមូលស្មើនឹង១២៥លានដុល្លារអាមេរិក នៅឆ្នាំ២០១៣ ទៅដល់ប្រមាណចំនួន **២ ២៧៩ ប៊ីលានរៀល** ឬសមមូលស្មើនឹង៥៦២លានដុល្លារអាមេរិក នៅឆ្នាំ២០២០, (២).ថវិការដ្ឋបាលក្រុង-ស្រុក ត្រូវ

បានបង្កើនពីប្រមាណតែចំនួន **៥៩ ប៊ីលានរៀល** ឬសមមូលស្មើនឹង ១៥ លានដុល្លារអាមេរិក នៅឆ្នាំ២០១៣ ទៅដល់ប្រមាណចំនួន **២៤៧ ប៊ីលានរៀល** ឬសមមូលស្មើនឹង ៦១ លានដុល្លារអាមេរិក នៅឆ្នាំ២០២០ និង (៣).ថវិការដ្ឋបាល ឃុំ-សង្កាត់ ត្រូវបានបង្កើនពីប្រមាណតែចំនួន **២០៤ ប៊ីលានរៀល** ឬសមមូលស្មើនឹង ៥១ លានដុល្លារអាមេរិក នៅឆ្នាំ២០១៣ ទៅដល់ប្រមាណចំនួន **៨០៣ ប៊ីលានរៀល** ឬសមមូលស្មើនឹង ១៩៨ លានដុល្លារអាមេរិក នៅឆ្នាំ២០២០។

ជាមួយនឹងការបង្កើនចំណាយដើម្បីលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍន៍នៅរដ្ឋបាលថ្នាក់ក្រោមជាតិ, អាទិភាពចំណាយត្រូវបានផ្តល់ដល់ការដំឡើងប្រាក់បំណាច់ជូនដល់ក្រុមប្រឹក្សារាជធានី-ខេត្ត, ក្រុង-ស្រុក-ខណ្ឌ, ឃុំ-សង្កាត់ និងមន្ត្រីភូមិផងដែរ។

### ៤.២.៣-ស្ថានភាពបំណុល

ក្នុងការគ្រប់គ្រងបំណុលសាធារណៈ រាជរដ្ឋាភិបាលប្រកាន់ខ្ជាប់នូវគោលការណ៍គន្លឹះចំនួន ៥ ដូចខាងក្រោម៖

(១). ខ្ចីឥណទានក្នុងទំហំសមស្របដែលស្ថានភាពថវិកា និងសេដ្ឋកិច្ចអាចទ្រាំទ្របាន

(២). ខ្ចីតែឥណទានដែលមានកម្រិតសម្បទាន ឬលក្ខខណ្ឌអនុគ្រោះខ្ពស់

(៣). ខ្ចីសម្រាប់តែវិស័យអាទិភាពទ្រទ្រង់ចីរភាពនៃកំណើនសេដ្ឋកិច្ច និងវិស័យបង្កើនផលិតភាពសេដ្ឋកិច្ច ឬផលិតភាពផលិតកម្ម

(៤). ប្រើប្រាស់ឥណទាន ប្រកបដោយតម្លាភាព, គណនេយ្យភាព, ប្រសិទ្ធភាព, និងស័ក្តិសិទ្ធភាពខ្ពស់បំផុត

(៥). ប្រើប្រាស់ឥណទានសម្រាប់ហិរញ្ញប្បទានគម្រោងវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសាធារណៈដែលត្រូវមានស្តង់ដា និងគុណភាពខ្ពស់ ស្របតាមគោលការណ៍នៃការគ្រប់គ្រងការវិនិយោគសាធារណៈ ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍជាតិនៅក្នុងដំណាក់កាលថ្មី ពិសេសជានាបាននូវចីរភាពសេដ្ឋកិច្ច, សង្គម, បរិស្ថាន, និងភាពធន់នឹងបម្រែបម្រួលអាកាសធាតុ។

រាជរដ្ឋាភិបាលកំណត់ទំហំនៃការខ្ចីប្រាក់ពីដៃគូអភិវឌ្ឍន៍សម្រាប់ឆ្នាំ ២០២០ ក្នុងកម្រិត ១ ៤00 លាន SDR ដោយសំអាងទៅលើទិដ្ឋភាពសំខាន់ៗគឺ៖ (១)-កំណើនតម្រូវការទុនវិនិយោគដ៏គំហុក ក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ និងសេវាសាធារណៈ ទាំងទំហំ, បរិមាណ, និងគុណភាព សម្រាប់ជំរុញការហក់ឡើងនៃសេដ្ឋកិច្ចនៅក្នុងដំណាក់កាលថ្មី និងក្នុងបរិបទនៃភាពមិនច្បាស់លាស់ (២)-គម្រោងអភិវឌ្ឍន៍ដែលនឹងចុះកិច្ចព្រមព្រៀងឥណទានសម្បទានក្នុងឆ្នាំ ២០២០ គឺជាគម្រោងវិនិយោគសាធារណៈក្នុងវិស័យអាទិភាព (ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ការបង្កើនផលិតភាពសេដ្ឋកិច្ច និងផលិតភាពផលិតកម្ម) ហើយដែលចេះតែរំកិលពីឆ្នាំមុនៗមក តែមានចរិតយុទ្ធសាស្ត្រក្នុងការទ្រទ្រង់ដល់ចីរភាពនៃកំណើនសេដ្ឋកិច្ចក្នុងរយៈពេលមធ្យម និងវែង (៣)-សុទ្ធសឹងតែជាឥណទានដែលមានកម្រិតសម្បទានខ្ពស់ (៤)-ស្ថានភាពបំណុលសាធារណៈកម្ពុជាបច្ចុប្បន្ន និងក្នុងរយៈពេលមធ្យមនិងវែង នៅតែមានចីរភាព និងហានិភ័យកម្រិតទាប និង (៥)-ការបន្តបង្កើនប្រសិទ្ធភាពខ្ពស់ក្នុងការគ្រប់គ្រង និងការអនុវត្តគម្រោង។ ជារួម ទំហំនៃការខ្ចីនេះ នឹងមិនបង្កើតជាបន្ទុកបំណុលវ័ណ្ឌករដល់កម្ពុជាទេ ព្រោះថា

នៅពេលដែលសេដ្ឋកិច្ចមានការរីកចម្រើននោះសមត្ថភាពសងរបស់កម្ពុជាក៏ខ្ពស់ជាងមុនដែរ។ ជាក់ស្តែង ផ្អែកលើលទ្ធផលនៃការវិភាគចីរភាពបំណុល ដោយឈរលើមូលដ្ឋានសន្មតិនៃការខ្ចីថ្មីបន្ថែមសម្រាប់ឆ្នាំ ២០២០ ក្នុងកម្រិត ១ ៤០០ លាន SDR គឺបានបង្ហាញថាសូចនាករបំណុលគន្លឹះទាំង ៤ របស់កម្ពុជា សុទ្ធតែស្ថិតក្រោមអនុបាតគោលទាំងអស់។

ក្នុងន័យនេះ ការកំណត់ពិដានក្នុងការខ្ចីថ្មីសម្រាប់ឆ្នាំ ២០២០ ក្នុងកម្រិត ១ ៤០០ លាន SDR គឺ ដើម្បីឱ្យរាជរដ្ឋាភិបាលអាចចុះហត្ថលេខាខ្ចីប្រាក់ពីគេបានចំនួន ២៩គម្រោង ក្នុងចំណោមគម្រោងសរុបចំនួន៣២ ដែលមានលក្ខណៈសម្បត្តិរួចរាល់ រួមមាន ធនាគារពិភពលោកចំនួន ៣គម្រោង ធនាគារអភិវឌ្ឍន៍អាស៊ីចំនួន ៧គម្រោង, ធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ចំនួន ១គម្រោង, សាធារណរដ្ឋប្រជាមានិតចិនចំនួន ៨គម្រោង, ប្រទេសជប៉ុនចំនួន ២គម្រោង, សាធារណរដ្ឋកូរ៉េចំនួន ៣គម្រោង, សាធារណរដ្ឋបារាំងចំនួន ៣គម្រោង, ព្រះរាជាណាចក្រថៃចំនួន ១គម្រោង, និងសាធារណរដ្ឋឥណ្ឌាចំនួន ១គម្រោង ក្នុងគោលដៅទ្រទ្រង់ចីរភាពនៃកំណើនសេដ្ឋកិច្ចរយៈពេលមធ្យម និងវែង និងការលើកកម្ពស់ភាពប្រកួតប្រជែង ព្រមទាំងផលិតភាពសេដ្ឋកិច្ច ដោយត្រូវបានបែងចែកតាមវិស័យដូចខាងក្រោម៖

- **វិស័យថាមពល៖** គម្រោងពង្រីកប្រព័ន្ធខ្សែបញ្ជូន និងចែកចាយនៅរាជធានីភ្នំពេញ ជំហានទី២ គម្រោងពង្រីកខ្សែបញ្ជូនអគ្គិសនីជនបទ ជំហានទី៧ គម្រោងសាងសង់ខ្សែបណ្តាញថាមពលអគ្គិសនីតង់ស្យុង១១៥គីឡូវ៉ុល ពីក្រុងសួង ខេត្តត្បូងឃ្មុំទៅស្រុកស្វាយអន្ទរខេត្តព្រៃវែង គម្រោងសាងសង់អនុស្ថានីយ៍បន្ថែមនៅតំបន់ជុំវិញរាជធានីភ្នំពេញ គម្រោងធ្វើទំនើបកម្មលើប្រព័ន្ធបណ្តាញបញ្ជូន និងចែកចាយ ក្នុងគោលដៅពង្រីកវិសាលភាពនៃការផ្គត់ផ្គង់អគ្គិសនី និងបញ្ចុះថ្លៃអគ្គិសនីនៅជនបទ ដើម្បី រួមចំណែកកាត់បន្ថយចំណាយរបស់ប្រជាជននៅជនបទផង និងកាត់បន្ថយថ្លៃដើមផលិតកម្មក្នុងវិស័យកសិកម្ម និងសិប្បកម្ម/ឧស្សាហកម្មជនបទផង;
- **វិស័យធារាសាស្ត្រ៖** គម្រោងអភិវឌ្ឍន៍ប្រព័ន្ធស្រោចស្រព និងការពារទឹកជំនន់ស្ទឹងព្រែកត្នោត រាជធានីភ្នំពេញ ខេត្តកណ្តាលនិងខេត្តតាកែវ និងគម្រោងអភិវឌ្ឍន៍អាងទឹកដងកាំបិត ខេត្តកំពង់ធំ;
- **វិស័យហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តៈ** គម្រោងសាងសង់ផ្លូវជាតិលេខ៧១ (ត្បូងឃ្មុំ-ក្រូចឆ្មារ-ចំការលើ), គម្រោងសាងសង់ផ្លូវជាតិលេខ៦០បេ ប្រវែង១១៦គម និងស្ពានមេគង្គក្រចេះ, គម្រោងរៀបចំច្រកទ្វារអន្តរជាតិស្ទឹងបត់ និងផ្លូវតភ្ជាប់ផ្លូវជាតិលេខ៥ ជំហានទី២, គម្រោងធ្វើឱ្យប្រសើរឡើងនូវកំណាត់ផ្លូវជាតិលេខ៥ ភាគខាងត្បូង, គម្រោងធ្វើឱ្យប្រសើរឡើងផ្លូវជាតិលេខ៤១ (ថ្នល់ទទឹង ផ្លូវជាតិលេខ៤-ផ្លូវជាតិលេខ៣ គម ១២៦+៧៥៥), គម្រោងធ្វើឱ្យប្រសើរឡើងផ្លូវជាតិលេខ៣៣ (ផ្លូវជាតិលេខ៣ គម ១៤៨+១០០-ព្រំប្រទល់កម្ពុជា វៀតណាម), គម្រោងធ្វើឱ្យប្រសើរឡើងផ្លូវជាតិលេខ៣១ (បែកគូស កំពង់ត្រាច-ផ្លូវជាតិលេខ៣៣ ), គម្រោងសាងសង់ផ្លូវវាងក្រុងសៀមរាប, គម្រោងសាងសង់ស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់ និងបណ្តាញលូនៅខេត្តសៀមរាប ជំហានទី២ និងកម្មវិធីអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទធន់នឹងការប្រែប្រួលអាកាសធាតុ;
- **វិស័យអាទិភាពផ្សេងទៀត៖** គម្រោងក្នុងវិស័យកសិកម្ម សុខាភិបាល ការផ្គត់ផ្គង់ទឹកស្អាត ហិរញ្ញវត្ថុ បណ្តុះបណ្តាលវិជ្ជាជីវៈ និងអប់រំ។

# សន្និធិបំណុលសាធារណៈក្រៅប្រទេស គិតត្រឹមដំណាច់ឆមាសទី១ ឆ្នាំ ២០១៩




## អនុបាតបំណុលគន្លឹះទាំង ៤



## ៥- សេចក្តីសន្និដ្ឋាន

ថវិកាឆ្នាំ ២០២០ ត្រូវបានរៀបចំក្រោមការគិតគូរប្រកបដោយភាពប្រយ័ត្នប្រយែង និងត្រូវបានវិភាជសម្រាប់អនុវត្តសកម្មភាពដែលឆ្លើយតបនឹងអាទិភាពគោលនយោបាយធំៗរបស់រាជរដ្ឋាភិបាល និងតម្រូវការចាំបាច់ជាមូលដ្ឋានរបស់ក្រសួង-ស្ថាប័ននានា ជាពិសេសសម្រាប់ការអនុវត្តឱ្យចេញជាលទ្ធផលជាក់ស្តែងប្រកបដោយប្រសិទ្ធភាពនូវ**កម្មវិធីនយោបាយ** និង**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤ ព្រមទាំងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៩-២០២៣** របស់រាជរដ្ឋាភិបាលដែលជាមាគ៌ារយៈពេលមធ្យម ដើម្បីឈានទៅសម្រេចបាននូវបំណងប្រាថ្នារយៈពេលវែងរបស់ប្រជាជនកម្ពុជា។ ក្នុងន័យនេះ ថវិកាឆ្នាំ ២០២០ នឹងដើរតួនាទីជាឧបករណ៍ដ៏មានប្រសិទ្ធភាពមួយក្នុងការជួយឱ្យរាជរដ្ឋាភិបាលអាចឆ្លើយតបទៅនឹងបញ្ហាប្រឈម និងហានិភ័យទាំងក្នុង និងក្រៅប្រទេស ហើយក៏ឆ្លើយតបទៅនឹងបំណងប្រាថ្នារបស់ប្រជាជន ក៏ដូចជាជួយឱ្យកម្ពុជាអាចសម្រេចបុព្វហេតុចម្បងៗរបស់ខ្លួន ជាពិសេសការបង្កើនល្បឿននៃការអភិវឌ្ឍ, ការលើកកម្ពស់ប្រសិទ្ធភាពសេវាសាធារណៈ និងការចូលរួមដោះស្រាយបញ្ហាជាច្រើនទៀតរបស់ជាតិ និងប្រជាជន ដែលស្តែងឡើងតាមរយៈការបន្តដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការទូទៅឱ្យកាន់តែខ្ពស់ជាង ១ លានរៀល ក្នុងឆ្នាំ ២០២០ និងការបង្កើនការផ្តល់នូវមធ្យោបាយ និងធនធានសមស្របដល់ក្រសួង-ស្ថាប័ន ដើម្បីបំពេញភារកិច្ចរបស់ខ្លួនស្របតាមទិសដៅនៃការកែទម្រង់ស៊ីជម្រៅឱ្យកាន់តែមានប្រសិទ្ធភាព ព្រមទាំងបន្តគាំទ្រការវិនិយោគចាំបាច់នានាដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ច ។

សរុបមក, ថវិកាឆ្នាំ ២០២០ គឺត្រូវបានរៀបចំឡើងតាមគោលនយោបាយវិត្តារកម្មថវិកា ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសលើមនុស្ស និងការកែទម្រង់រចនាសម្ព័ន្ធ ដែលមានអភិបាលកិច្ចជាស្នូលហើយអាចប្រសិទ្ធនាមបានថាជា "**ថវិកាយុទ្ធសាស្ត្រនៃការផ្តួបកម្លាំងសរុប ដើម្បីទប់ទល់នឹងបញ្ហាប្រឈម និងហានិភ័យទាំងក្នុង និងក្រៅប្រទេស តាមរយៈការពង្រឹងសមត្ថភាពផ្ទៃក្នុង ដោយជំរុញឱ្យបានខ្លាំងក្លានូវការកែទម្រង់ស៊ីជម្រៅ និងមុតស្រួច ដើម្បីធានាសុខសន្តិភាព ស្ថិរភាព និងចីរភាពនៃកំណើនសេដ្ឋកិច្ច សំដៅលើកកម្ពស់សុខុមាលភាពជូនប្រជាជន លើមាគ៌ាឆ្ពោះទៅរកចក្ខុវិស័យឆ្នាំ ២០៣០ និងឆ្នាំ ២០៥០**" ។

*ថ្ងៃសុក្រ ១២រោច ខែអស្សុជ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣*

*រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៩*

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**